**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍
# ប្រជុំរួមប្រចាំខែ មីនា ឆ្នាំ ២០១៤

នៅថ្ងៃទី៣១ ខែ មីនា ឆ្នាំ ២០១៤ វេលាម៉ោង ០៩:០០នាទីព្រឹក នៅអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំមន្ត្រីរាជការ បុគ្គលិកទាំងអស់ប្រចាំខែមីនា ឆ្នាំ២០១៤ ដែលដឹកនាំការប្រជុំដោយ **ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះ មានៈ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ និង មន្ត្រីរាជការបុគ្គលិកទាំងអស់ ចំនួន ៥៥ នាក់ ។

**អវត្តមាន**

| | | | |
|---|---|---|---|
| ១-ឯកឧត្តមវេជ្ជ | ហោ ប៊ុនឡេង | អគ្គលេខាធិការរង | (ជួបឯ.ឧ ទេស) |
| ២-លោកស្រីវេជ្ជ. | ងិន លីណា | ប្រធាននាយកដ្ឋានPMER | (ច្បាប់) |
| ៣- លោកវេជ្ជ. | អ៊ុក ម៉ារឌី | អនុប្រធាននាយកដ្ឋាន PCS | (ឥតច្បាប់) |
| ៤-លោក | នាង សៅវុធី | ប្រធានការិយាល័យបុគ្គលិក | (ឥតច្បាប់) |
| ៥-លោក | ឡាច ឈុនលី | មន្ត្រីនាយកដ្ឋាន AF | (ឥតច្បាប់) |
| ៦-លោកស្រី | សោម ប៉ូលីន | មន្ត្រី | (ឥតច្បាប់) |
| ៧-លោក | ចេង ថា | មន្ត្រី | (ឥតច្បាប់) |
| ៨-លោក | ទុយ អមរិទ្ធ | មន្ត្រី | (ឥតច្បាប់) |
| ៩-លោកស្រី | ប៉ែន អ៊ុងវិរ៉ា | មន្ត្រី | (ឥតច្បាប់) |

គោលបំណងនៃកិច្ចប្រជុំនេះ មានៈ

1. ការងារបច្ចេកទេស
2. ការការងាររដ្ឋបាល

- ការពិភាក្សាពីការរៀបចំអបអរសាទរពិធីសុត្រមន្តបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំមមី ។

3. ការងារផ្សេងៗ

ជាកិច្ចចាប់ផ្តើម ឯកឧត្តមអគ្គលេខាធិការ ក៏មានមតិស្វាគមន៍ និង កោតសរសើរដល់មន្ត្រី ដែលបានខិតខំបំពេញការងារ និង ជំរុញលើកទឹកចិត្តដល់មន្ត្រី បុគ្គលិកទាំងអស់ ឲ្យប្រឹងប្រែងធ្វើការងារ បន្តទៅទៀត ។

ការងារបច្ចេកទេស

- ចំពោះ GARPR ត្រូវបញ្ជូនឲ្យគេ នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ តែត្រូវបានគេពន្យាពេលឲ្យមួយសប្តាហ៍ទៀត( ២ឆ្នាំធ្វើម្តង ) ។
- របាយការណ៍ប្រចាំខែ ស្នើនាយកដ្ឋាននីមួយៗ បញ្ជូនមកឲ្យនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និង ស្រាវជ្រាវសរុប ឲ្យបានមុនថ្ងៃទី ២៥ នៃខែនីមួយៗ ។
- ចំពោះនាយកដ្ឋានណា មិនបានបញ្ជូនមកឲ្យនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និង ស្រាវជ្រាវទេ នោះប្រធាននាយកដ្ឋាន ជាអ្នកទទួលខុសត្រូវ ។

ការពិភាក្សា

លោក **ឈឹម ឃិនដារ៉េត** ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ បានលើកឡើងថា

- ស្នើនាយកដ្ឋាននីមួយៗ ដែលមានការជ្រើសរើស TA ត្រូវរៀបចំបែបបទ ដើម្បីជ្រើសរើស ។
- នាយកដ្ឋាននីមួយៗ ត្រូវរៀបចំថវិកាឆ្នាំ ២០១៥ ដើម្បីឆ្លើយតបទៅនឹងការកំណែទំរង់ហិរញ្ញវត្ថុឆ្នាំ ២០១៥ ។

ឯកឧត្តមវេជ្ជ. **ស៊ឹម គឹមសាន** ប្រធាននាយកដ្ឋានទាក់ទង និង ចលនាប្រភពធនធាន បានលើកឡើងថា ៖

- នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ដែលជានាយកដ្ឋានជំនាញ ត្រូវយកទំរង់បែបបទនៃការកំណែទំរង់ថវិកាឆ្នាំ ២០១៥ ឲ្យបានច្បាស់លាស់ ដើម្បីរៀបចំនូវផែនការសកម្មភាព ។

ឯកឧត្តមអគ្គលេខាធិការ បានមានអនុសាសន៍

- ស្នើឲ្យនាយកដ្ឋាននីមួយៗ រៀបចំផែនការថវិកាឆ្នាំ ២០១៥
- ស្នើនាយកដ្ឋាននីមួយៗ រៀបចំផែនការសកម្មភាពរបស់នាយកដ្ឋានឲ្យហើយទៅ ។ ប្រធាននាយកដ្ឋាន ត្រូវទទួលខុសត្រូវចំពោះផែនការសកម្មភាពរបស់ខ្លួនសំរាប់ថវិកាឆ្នាំ ២០១៥ មិនឲ្យជាន់ជាមួយសកម្មភាពអនុវត្តរបស់ថវិកាមូលនិធិសកល ។
- រៀងរាល់ថ្ងៃប្រជុំទាំងអស់ ស្នើឲ្យមន្ត្រី បុគ្គលិក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវមានវត្តមាននៅក្នុងពេលប្រជុំ ។

**ការងាររដ្ឋបាល**

**លោក ឈឹម ឃិនដារ៉េត** ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ក៏បានលើកឡើងនូវការងារមួយចំនួន ជូនសមាជិក បានយល់ និង ត្រូវអនុវត្ត ដែលមានដូចខាងក្រោម ៖

- មន្ត្រីទាំងអស់ ត្រូវគោរពវិន័យក្នុងម៉ោងធ្វើការងារ និង មានវត្តមានរៀងរាល់ប្រជុំ (ប្រចាំសប្តាហ៍ ខែ និង ថ្នាក់ដឹកនាំ )។
- មន្ត្រីដែលអវត្តមានក្នុងពេលប្រជុំ ត្រូវមានច្បាប់អនុញ្ញាតិជាលាយល័ក្សអក្សរត្រឹមត្រូវ ។
- ស្នើមន្ត្រី បុគ្គលិក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ត្រូវចូលរួមអបអរសាទរពិធីសូត្រមន្តចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំមមី នៅថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៤ វេលាម៉ោង ២: ០០នាទីរសៀល ។

**ឯកឧត្តមអគ្គលេខាធិការ** ផ្តល់ជាអនុសាសន៍ ៖

- មន្ត្រី បុគ្គលិក ទាំងអស់នៅក្នុងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវចូលរួមប្រជុំប្រចាំខែ(សប្តាហ៍ទី៤ នៃខែនីមួយៗ ) ។ បើមន្ត្រី បុគ្គលិកណា អវត្តមានត្រូវមានលិខិតសុំច្បាប់អនុញ្ញាតិត្រឹមត្រូវ ។
- មន្ត្រី បុគ្គលិក ដែលអវត្តមាននៅក្នុងពេលប្រជុំ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវធ្វើលិខិតអញ្ជើញប្រជុំជាលើកទី២ ។
- នៅថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៤ មានរៀបចំពិធីអបអរសាទរពិធីសូត្រមន្តចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំមមី ហើយប្រមាណជាវេលាម៉ោង ៤: ៣០នាទី

រសៀល មានកម្មវិធីជូនពរថ្នាក់ដឹកនាំ ដូចនេះស្នើមន្ត្រី បុគ្គលិកទាំងអស់ចូលរួមក្នុងពិធីជូនពរនេះ ។

- នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ស្នើរៀបចំជាកាដូជូនពរថ្នាក់ដឹកនាំ ។
- នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវពិនិត្យមើលលទ្ធភាព ដើម្បីអញ្ជើញដៃគូចូលរួមនៅក្នុងពិធីអបអរសាទរពិធីសូត្រមន្តចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំមមី ។
- នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវពង្រឹងយន្តការបែបបទបុគ្គលិកចូលបំរើការងារថ្មី ។

ជាចុងក្រោយ ឯកឧត្តមអគ្គលេខាធិការ បានស្នើឲ្យមន្ត្រី បុគ្គលិកទាំងអស់ ខិតខំអនុវត្តការងារ ប្រកបដោយសាមគ្គីភាព ចេះជួយគ្នាទៅវិញទៅមក ពង្រឹងការផ្តល់ព័ត៌មានឲ្យបានច្បាស់ ទាន់ពេលវេលា និង មានវិន័យក្នុងការងារ ការប្រជុំជាមួយថ្នាក់ដឹកនាំជាដើម ។ ជំរះឲ្យបាននូការមើលបំណាំគ្នា ឬ ក៏ចាប់កំហុសគ្នាទៅវិញទៅមក ។ ត្រូវផ្តល់មតិយោបល់គ្នាក្នុងនាមជាគ្រួសារមិត្តភ័ក្តរួមការងារ ។

អង្គប្រជុំបានបញ្ចប់ នៅវេលាម៉ោង ១១:០០នាទី នាថ្ងៃ ខែ ឆ្នាំដដែល ប្រកបដោយបរិយាកាស រីករាយក្រៃលែង៕

**អ្នកធ្វើរបាយការណ៍**

ហ៊ុន ស

បានឃើញ និង ឯកភាព

**ប្រធានអង្គប្រជុំ**

វេជ្ជ. តែន គន្ធិ